ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

*ថ្ងៃព្រហស្បតិ៍ ៤កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦*
*រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០២៣*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ការចុះអនុស្សរណៈយោគយល់ស្តីពី
# "កិច្ចសហប្រតិបត្តិការក្នុងផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុនិងប្រព័ន្ធទូទាត់សងប្រាក់"
# រវាង
# ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលកោះសូឡូម៉ូន
# និង ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលហ្វីជី

នាថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជា បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ (MoU) ចំនួនពីរ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់ជាមួយធនាគារកណ្តាលនៃកោះសូឡូម៉ូន និងធនាគារកណ្តាលហ្វីជី។ ពិធីចុះហត្ថលេខានេះធ្វើឡើងនៅរាជធានីភ្នំពេញ ដោយ ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ជាមួយឯកឧត្តម Luke Forau ទេសាភិបាល ធនាគារកណ្តាលនៃកោះសូឡូម៉ូន និង ឯកឧត្តម Esala Masitabua ទេសាភិបាលរងនៃធនាគារកណ្តាលហ្វីជី។

ថ្លែងក្នុងសុន្ទរកថាស្វាគមន៍ ឯកឧត្តម ជា ចាន់តូ បានលើកឡើងថា ការចុះហត្ថលេខាលើអនុស្សរណៈយោគយល់នេះ គឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយសម្រាប់ធនាគារកណ្តាលទាំងបី ដើម្បីសម្រេចបាននូវកិច្ចសហប្រតិបត្តិការក្នុងផ្នែកហិរញ្ញវត្ថុឱ្យបានកាន់តែល្អមួយកម្រិតទៀត តាមរយៈការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីផ្តល់ផលប្រយោជន៍ដល់ប្រជាជនក្នុងប្រទេសនីមួយៗ។

ឯកឧត្តម ជា ចាន់តូ បានមានប្រសាសន៍ថា "គោលបំណងសំខាន់នៃអនុស្សរណៈយោគយល់នេះគឺការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍលើផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់ ព្រមទាំងដើម្បីចែករំលែកព័ត៌មានពាក់ព័ន្ធស្តីអំពីនវានុវត្តន៍ និងការទូទាត់តាមបែបឌីជីថលសម្រាប់សេវាកម្មហិរញ្ញវត្ថុ។ អនុស្សរណៈយោគយល់នេះនឹងផ្តល់ជាក្របខ័ណ្ឌជំរុញកិច្ចសហប្រតិបត្តិការតាមរយៈការផ្លាស់ប្តូរចំណេះដឹង និងបទពិសោធន៍ ដល់គ្នាទៅវិញទៅមក"។

ឯកឧត្តម Luke Forau ទេសាភិបាល ធនាគារកណ្តាលកោះសូឡូម៉ូន បានសម្តែងនូវអារម្មណ៍រីករាយយ៉ាងខ្លាំងលើកិច្ចសហប្រតិបត្តិការជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីសិក្សាអំពីបទពិសោធន៍របស់កម្ពុជាក្នុងការប្រើប្រាស់បច្ចេកវិទ្យាដើម្បីទាញយកផលប្រយោជន៍សម្រាប់ប្រជាជនកោះសូឡូម៉ូន។

ឯកឧត្តម Luke Forau បានមានប្រសាសន៍ថា "ប្រទេសកម្ពុជាបានផ្តល់ឱកាសឱ្យយើងស្វែងយល់ពីការដឹកនាំរបស់ធនាគារជាតិនៃកម្ពុជាលើការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ព្រមទាំងបានផ្តល់ការគាំទ្របន្ថែម តាមរយៈការចុះអនុស្សរណៈនៃការយោគយល់ក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍប្រព័ន្ធទូទាត់ ដែលអាចឱ្យសាធារណជនធ្វើការទូទាត់ និងទទួលបានមូលនិធិងាយស្រួលនិងភ្លាមៗ"។ ទន្ទឹមនេះ ឯកឧត្តម Luke Forau បានគោរពអញ្ជើញ ឯកឧត្តម ជា ចាន់តូ បំពេញទស្សនកិច្ចនៅកោះសូឡូម៉ូន ដើម្បីចូលរួមកិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលប៉ាស៊ីហ្វិកខាងត្បូងលើកទី៣៨ ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងហូនីអារ៉ា កោះសូឡូម៉ូន ដើម្បីចែករំលែកបទពិសោធន៍របស់កម្ពុជាដល់ប្រទេសជាសមាជិកដទៃទៀតដែលមកពីតំបន់ប៉ាស៊ីហ្វិកខាងត្បូង។

ឯកឧត្តម Esala Masitabua ទេសាភិបាលរង ធនាគារកណ្តាលហ្វីជី បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ធនាគារជាតិនៃកម្ពុជាចំពោះទឹកចិត្តក្នុងការចែករំលែកបទពិសោធន៍ និងចំណេះដឹងក្នុងការប្រើប្រាស់បច្ចេកវិទ្យាដើម្បីអភិវឌ្ឍប្រព័ន្ធទូទាត់។

ឯកឧត្តម Esala Masitabua បានមានប្រសាសន៍ថា "អនុស្សរណៈនៃការយោគយល់នេះបានផ្តល់នូវក្របខ័ណ្ឌសម្រាប់ការចែករំលែកព័ត៌មាន និងកិច្ចសហប្រតិបត្តិការដោយបើកចំហ ដែលនឹងជួយដល់ប្រទេសហ្វីជីក្នុងដំណើរការអភិវឌ្ឍប្រព័ន្ធទូទាត់ឌីជីថលដែលទំនើប មានប្រសិទ្ធភាពនិងអាចទុកចិត្តបាន សម្រាប់គាំទ្រដល់តម្រូវការរបស់ប្រជាជនហ្វីជី។ កិច្ចសហប្រតិបត្តិការនេះក៏នឹងគាំទ្របន្ថែមទៀតដល់ការកែទម្រង់ប្រព័ន្ធទូទាត់ជាតិដែលកំពុងដំណើរការ និងអនុញ្ញាតឱ្យហ្វីជីអាចរីកចម្រើនបានលឿនក្នុងការប្រើប្រាស់បច្ចេកវិទ្យាដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ។"

ប្រព័ន្ធបាគងរបស់ធនាគារជាតិនៃកម្ពុជា គឺជាគម្រោងដែលបានប្រើប្រាស់ផ្លែតហ្វមបច្ចេកវិទ្យាដើម្បីលើកកម្ពស់ការតភ្ជាប់ និងការធ្វើប្រតិបត្តិការឆ្លងគ្រឹះស្ថាន ដើម្បីពង្រឹងប្រសិទ្ធភាព ប្រព័ន្ធទូទាត់និង ដើម្បីរួមចំណែកលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងការប្រើប្រាស់ប្រាក់រៀល។ បច្ចុប្បន្នប្រព័ន្ធបាគងមានគ្រឹះស្ថានជាសមាជិកចំនួន ៧០។

**ទំនាក់ទំនង ៖**

ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា

ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៩០ ១៩៦

អ៊ីម៉ែល ៖ nbccommunication@nbc.gov.kh

**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**

www.nbc.gov.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA